ជស/រកត/១២ ៩៧/២៧៣

# ព្រះរាជក្រឹត្យ

## ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

យើង

ព្រះបាទសម្តេចព្រះនរោត្តមសីហនុ

រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី ទី ១ និង នាយករដ្ឋមន្ត្រី ទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/ ០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ និង ពីរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្របតាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។

ត្រាស់បង្គាប់

## ជំពូក ទី ១
## បទបញ្ញត្តិទូទៅ

មាត្រា ១ : មន្ត្រីរាជការស៊ីវិលទាំងអស់ត្រូវបានរៀបចំជា ក្របខ័ណ្ឌ ដែលត្រូវបែងចែកជា ឋានន្តរស័ក្តិ ។ ក្របខ័ណ្ឌត្រូវចាត់ថ្នាក់ទៅតាម ប្រភេទ ។

## ជំពូក ទី ២
## អំពីប្រភេទ

មាត្រា ២ : ក្របខ័ណ្ឌ មន្ត្រីរាជការស៊ីវិលទាំងអស់ ត្រូវបែងចែកជា ៤ ប្រភេទ ក .ខ. គ. និង ឃ ដែលកំណត់ឡើង ដោយយោងទៅតាមល័ក្ខខ័ណ្ឌអប្បបរិមានៃការបណ្តុះបណ្តាល សំរាប់បញ្ចូលក្នុងក្របខ័ណ្ឌ និង កំរិតឋានានុក្រមនៃតំណែង របស់ក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយៗ ចាំបាច់ត្រូវចាត់បញ្ចូលទៅក្នុងប្រភេទណាមួយនៃប្រភេទទាំង ៤ តាមលក្ខន្តិកៈដោយឡែករបស់ខ្លួន ។

មាត្រា ៣ : មន្ត្រីរាជការប្រភេទ ក មានមុខងារក្នុងតំណែង ដឹកនាំ អធិការកិច្ច សិក្សា និងផ្តល់យោបល់ និង មុខងារក្នុងរាល់តំណែង ទទួលខុសត្រូវ ។ កំរិតអប្បបរិមានៃការបណ្តុះបណ្តាល ដើម្បីអាចបញ្ចូល ក្របខ័ណ្ឌក្នុងប្រភេទ ក គឺ សញ្ញាប័ត្រមធ្យមសិក្សាកំរិ[redacted] នៃការសិក្សា ដោយមានសញ្ញាប័ត្រ ។ លក្ខន្តិកៈដោយឡែកខ្លះអាច ប្រសិនបើ ចាំបាច់ តម្រូវនូវកំរិតអប្បបរិមានៃការបណ្តុះបណ្តាលស្មើ ឬ លើសសញ្ញាប័ត្រមធ្យមសិក្សាកំរិ[redacted] នៃការសិក្សា ដោយមានសញ្ញាប័ត្រ ។ ក្នុងករណីនេះ ត្រូវមានផ្តល់នូវការ[redacted] ។

មាត្រា ៤ : ប្រភេទ ខ មានមុខងារក្នុង ការរៀបចំការងារ សំរាប់អ្នកទទួលខុសត្រូវ សំរេច និង ដាក់អោយអនុវត្ត ។ កំរិតអប្បបរិមា ដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ ខ គឺសញ្ញាប័ត្រមធ្យមសិក្សា[redacted]នៃការសិក្សាដោយមាន សញ្ញាប័ត្រ ។

មាត្រា ៥ : ប្រភេទ គ មានមុខងារក្នុង លេខាធិការដ្ឋាន និង មុខងារប្រតិបត្តិដែលតម្រូវអោយមានចំណេះ បច្ចេកទេស ឬចំណេះធ្វើការងារ ។ កំរិតអប្បបរិមាដើម្បីបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទ គ [redacted]

មាត្រា ៦ : ប្រភេទ ឃ មានមុខងារក្នុង ការប្រតិបត្តិ ។ ការបញ្ចូលក្របខ័ណ្ឌទៅក្នុងប្រភេទនេះ ពុំតម្រូវអោយមាន [redacted] ។

មាត្រា ៧ : កំរិតអប្បបរិមានៃការបណ្តុះបណ្តាលដែលបានកំណត់ក្នុងមាត្រា ៣- ៤ និង ៥ នៃព្រះរាជក្រឹត្យនេះ ត្រូវអនុវត្ត ចំពោះនិស្សិតទាំងឡាយណា ដែលត្រូវបានជ្រើសរើសអោយចូលមុខងារសាធារណៈ តាមការប្រលងប្រជែងចាប់ពីថ្ងៃ ផ្សព្វផ្សាយព្រះរាជក្រឹត្យនេះ ។

មាត្រា ៨ : មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញការកិច្ចក្នុងមុខតំណែង តាមការតែងតាំងដែលមានរួចហើយ ត្រូវផ្ទេរចូលក្នុងក្របខ័ណ្ឌថ្មី ។ គណៈកម្មការអន្តរក្រសួងមួយ នឹងត្រូវបានតែងតាំងដោយអនុក្រឹត្យ ដើម្បីបើកដំណើរការ សំរាប់ការចាត់ថ្នាក់ថ្មីជូនរាជរដ្ឋាភិបាលពិនិត្យនិងសំរេច ។

## ជំពូក ទី ៣

## អំពីក្របខ័ណ្ឌ

មាត្រា ៩ : ក្របខ័ណ្ឌនីមួយ ១ នៃមន្ត្រីរាជការ គឺជាការប្រមូលផ្តុំភ្នាក់ងារ ដែលមានគុណសម្បត្តិ ឬ ការបណ្តុះបណ្តាលដូចគ្នា ហើយដែលមានឧបនិស្ស័យកាន់តំណែងដូចគ្នា ឬ ប្រភេទមុខតំណែងដូចគ្នា ក្នុងអាជីពរបស់ខ្លួននៅក្នុងក្រសួងណាមួយ ។

មាត្រា ១០ : ក្របខ័ណ្ឌនីមួយ១ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកមួយដែលរៀបចំដោយក្រសួងសាមី និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ លក្ខន្តិកៈដោយឡែកត្រូវកំណត់ឡើងដោយព្រះរាជក្រឹត្យ និងដោយមានការយល់ព្រមពីគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាល និង ពីក្រុមប្រឹក្សាអ្នកច្បាប់ ។

មាត្រា ១១ : លក្ខន្តិកៈដោយឡែកបង្កើតក្របខ័ណ្ឌនីមួយ ១ និង រៀបចំអាជីព ត្រូវស្របទៅតាមបទបញ្ញត្តិសហលក្ខន្តិកៈនៃមន្ត្រីរាជការស៊ីវិល និង តាមអត្ថបទថ្មីនេះ ។ លក្ខន្តិកៈដោយឡែក ត្រូវមានជាចាំបាច់នូវបទបញ្ញត្តិដូចតទៅ :

ក- ការភ្ជាប់ក្របខ័ណ្ឌក្នុងក្រសួងមួយ

ខ- ការចាត់ថ្នាក់ក្របខ័ណ្ឌទៅក្នុងប្រភេទមួយ

គ- ការកំណត់បេសកកម្មទូទៅរបស់ក្របខ័ណ្ឌ

ឃ- ការកំណត់មុខតំណែង ដែលភ្នាក់ងារក្របខ័ណ្ឌត្រូវបំពេញ

ង- ការកំណត់លក្ខណៈសម្បត្តិអប្បបរិមា ដើម្បីបញ្ចូលក្នុងក្របខ័ណ្ឌ និង របៀបបទនៃការប្រលងប្រជែងផ្ទៃក្នុង និង ការប្រលងប្រជែងចូលក្របខ័ណ្ឌរាជការដោយ ទិស្សិតសុទ្ធសាធ

ច- របបកម្មសិក្សាសាកល្បង

ឆ- ការកំណត់ឋានានុក្រមក្របខ័ណ្ឌ ( បែងចែកក្របខ័ណ្ឌជាឋានន្តរស័ក្តិ និងកំណត់មុខតំណែងសំរាប់ឋានន្តរស័ក្តិនីមួយ ១ )

ជ- វិធានសំរាប់តម្លើងថ្នាក់ និង តម្លើងឋានន្តរស័ក្តិ ។

មាត្រា ១២ : អនុក្រឹត្យមួយ នឹងកំណត់ខ្លឹមសារគំរូនៃលក្ខន្តិកៈដោយឡែក និងវិធីអនុវត្តដើម្បីបង្កើតក្របខ័ណ្ឌ ។

## ជំពូក ទី ៤

## អំពីឋានន្តរស័ក្តិ

មាត្រា ១៣ : ឋានន្តរស័ក្តិ គឺជាតំណាងឋានានុក្រមនៃក្របខ័ណ្ឌ ។ ក្របខ័ណ្ឌនីមួយ១ គឺអាចត្រូវបែងចែកជា ៣ ឋានន្តរស័ក្តិ

ឋានានុក្រម ។ ឋានន្តរស័ក្តិនីមួយ ១ ឆ្លើយតបទៅនឹងមុខតំណែង ឬ សារព័ន្ធមុខតំណែងដែលមានការទទួលខុសត្រូវកាន់តែខ្ពស់ ។

មាត្រា ១៤ : និស្សិតដែលមិនមែនជាមន្ត្រីរាជការ ហើយដែលត្រូវបានជ្រើសរើសតាមការប្រលងប្រជែង អោយចូលកាន់មុខងារសាធារណៈ ចាំបាច់ត្រូវតាំងស៊ប់ក្នុងឋានន្តរស័ក្តិដំបូងនៃក្របខ័ណ្ឌ ។

មាត្រា ១៥ : ជាធម្មតា ភ្នាក់ងារទាំងឡាយអាចមានឧបនិស្ស័យ សំរាប់ដំណើរការអាជីពរហូតក្នុងវិជ្ជាជីវៈរបស់ខ្លួនក្នុងឋានន្តរស័ក្តិដំបូង ដោយមានការតម្លើងថ្នាក់ជាទៀងទាត់ ទៅតាមបទបញ្ញត្តិនៃសហលក្ខន្តិកៈ និង លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌរបស់ខ្លួន ។

មាត្រា ១៦ : ការតម្លើងឋានន្តរស័ក្តិក្នុងឋានន្តរស័ក្តិ ទី ២ ទី ៣ គឺសំរាប់ភ្នាក់ងារណា ដែលមានគុណសម្បត្តិជាងគេ ។ ការតម្លើងឋានន្តរស័ក្តិនេះ ផ្អែកទៅលើភាពទំនេរនៃតំណែង ហើយប្រព្រឹត្តទៅតាមការចុះឈ្មោះក្នុងតារាង តម្លើងឋានន្តរស័ក្តិ ឬ តាមការទទួលបាន នូវវិញ្ញាបនប័ត្រសិក្សារយៈពេលវែង នៅសាលាភូមិន្ទរដ្ឋបាល ឬ សាលាអនុវត្ត ដែលទទួលស្គាល់ដោយលក្ខន្តិកៈដោយឡែក ឬ តាមការប្រលងប្រជែង ។ អាចត្រូវបានតម្លើង ឋានន្តរស័ក្តិ ទី ២ នៃក្របខ័ណ្ឌមួយ ចំពោះភ្នាក់ងារទាំងឡាយណា ដែលបានឡើងដល់ថ្នាក់ ទី ៤ នៃឋានន្តរស័ក្តិដំបូងរួចហើយ ។ អាចត្រូវបានតម្លើងទៅឋានន្តរស័ក្តិ ទី ៣ នៃក្របខ័ណ្ឌមួយ ចំពោះភ្នាក់ងារទាំងឡាយណា ដែលបានឡើងដល់ថ្នាក់ទី ៤ នៃឋានន្តរស័ក្តិ ទី ២ រួចហើយ ។ ការឡើងឋានន្តរស័ក្តិ ទៅឋានន្តរស័ក្តិខ្ពស់ជាងមួយទៀត ផ្តល់ឧបនិស្ស័យដល់សាមីជន ដើម្បីទទួលមុខតំណែងស្របទៅតាម ឋានន្តរស័ក្តិថ្មី ដូចដែលបានកំណត់ក្នុងលក្ខន្តិកៈដោយឡែក ។

មាត្រា ១៧ : បែបបទនៃការដាក់ចំនួនភ្នាក់ងារបច្ចុប្បន្នបញ្ចូលក្នុងឋានន្តរស័ក្តិថ្មីនៃក្របខ័ណ្ឌ និង អន្តរប្បញ្ញត្តិត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូក ទី ៥

## <u>អំពីថ្នាក់</u>

មាត្រា ១៨ : ឋានន្តរស័ក្តិនីមួយៗ ត្រូវបានបែងចែកជាថ្នាក់ ដែលមានសន្ទស្សន៍ កំណត់អំពីកំរិតលាភការ ។

មាត្រា ១៩ : ឋានន្តរស័ក្តិ ទី ១ ត្រូវបានចែកចេញជា ១៤ ថ្នាក់ ។ ឋានន្តរស័ក្តិ ទី ២ ចែកចេញជា ១០ ថ្នាក់ ។ ឋានន្តរស័ក្តិ ទី ៣ ចែកចេញជា ៦ ថ្នាក់ ។

មាត្រា ២០ : ជាធម្មតា មន្ត្រីរាជការទាំងអស់ ត្រូវបានតម្លើងថ្នាក់ក្នុង ២ ឆ្នាំ ម្តង វៀរលែងក្នុងករណីដែលត្រូវបានផ្តល់អត្ថប្រយោជន៍ ស្តីពីអតីតភាព ដែលជាលទ្ធផលចេញមកពីស្នាដៃពិសេស ឬ បើជាការចាំបាច់ពីភាពលំបាកពិសេសនៃការទទួលខុសត្រូវ ឬ ពីលក្ខណៈស្ថិតក្នុងតំបន់ដាច់ស្រយាលនៃមុខតំណែងខ្លះ ។ លក្ខន្តិកៈដោយឡែកត្រូវកំណត់ព្រំដែនជាក់លាក់នៃមុខតំណែង ដែលអាចផ្តល់អត្ថប្រយោជន៍លើ អតីតភាពថ្នាក់ ។